# ព្រះធាតុខ្វាន់ពីរ

ប្រាសាទនេះស្ថិតនៅក្នុងភូមិ១០៥ ឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ (មានចម្ងាយប្រហែល៥គ.ម.ពីភូមិ១០៥)។ កាលដែលខ្ញុំទៅមើលប្រាសាទនេះនៅឆ្នាំ២០១៦ មានការលំបាកបន្តិច ដោយសារគ្មានផ្លូវភ្ជាប់ទៅដិតប្រាសាទ ដូច្នេះហើយត្រូវការពេលយូរដើរកាត់ដុប ព្រៃ និងអូរច្រើនកន្លែង។ បើលោកអ្នកចង់ទៅមើលប្រាសាទនេះ គួររកអ្នកភូមិឱ្យនាំទៅជៀសវាងវង្វេងនាំឱ្យខាតពេលវាលា។

ប្រាសាទនេះមានភាពរិចរិលខ្លាំងដោយកត្តាធម្មជាតិ និងបាក់បែកដោយសារកត្តាមនុស្សបំផ្លាញ។ ដោយសារប្រាសាទនេះនៅឆ្ងាយពីភូមិ ឆ្ងាយពីភ្នែកច្រមុះរបស់អាជ្ញាធរសកម្មភាពលួច ជីកកកាយនៅតែមាន។ ទោះបីយ៉ាងនេះក្តី ប្រាសាទនេះនៅសល់ក្បាច់ចម្លាក់ដ៏ល្អៗដែលត្រូវតែថែរក្សា បើមិនដូច្នោះទេនឹងកាន់តែបាត់បង់ហើយ។

ប្រាសាទនេះសាងនៅលើដីទួលដែលគេលើក ធ្វើអំពីឥដ្ឋ មានតួប្រាសាទពីរបែរមុខទៅខាងកើត (រូបលេខ១)។ សព្វថ្ងៃនៅសល់តួប្រាសាទមួយនៅល្អមួយផ្នែក(រូបលេខ២-៣) និងមួយទៀតបាក់បែកអស់(រូបលេខ៤)។ តាមការដើរមើលប្រាសាទជាច្រើន កន្លងមកខ្ញុំយល់ថាឥដ្ឋដែលសាងប្រាសាទនេះមានគុណភាពល្អ។ ប្រាសាទនេះមានក្បាច់ចម្លាក់ស្អាតឆ្លាក់យ៉ាងលម្អិតនៅលើផ្តែរ ហោជាង ទ្វារបញ្ឆោត សសរផ្អោប សសរពេជ្រ និងប្រាសាទអណ្តែត[១] (រូបលេខ៥)។ល។ បើពិនិត្យមើលក្បាច់ភ្ញីនៅលើផ្តែរ និងសសរផ្អោបរបស់ប្រាសាទនេះគឺនៅក្នុងរចនាបថកំពង់ព្រះក្នុងរវាងដើមស.វ.ទី៨ (រូបលេខ៦)។

ម្យ៉ាងទៀតយោងតាមសិលាចារឹកភាសាសំស្ក្រឹតដែលមានចារពីរជួរ ហើយដែលគេបានផ្តិត និងបានបកប្រែដោយលោកល្វី ហ្វីណូ (Finot, L.) ដែលមានលេខចុះលេខបញ្ជី (K.121) បានសរសេរអំពីកាលបរិច្ឆេទ គឺនៅស.ក.៦៣៨ ត្រូវនឹងគ.ស.៧១៦ (រូបលេខ៧)។[២] នៅក្នុងសិលាចារឹកនេះមាននិយាយអំពីឈ្មោះ **បុស្ករ** (Puṣkara) ដែលបានសាងលិង្គមួយឈ្មោះ **ស្រីបុស្ករេស** (Puṣkareça) ដែលលោក **ហ្វីណូ** ឱ្យសេចក្តីសន្និដ្ឋានថា

[១] ទាក់ទងនឹងប្រាសាទអណ្តែត ឬវិមានអណ្តែត សូមមើល (ព្រាប ចាន់ម៉ារ៉ា ២០២០)

[២] Finot 1904: 675-76

អត្ថបទដោយ៖ ញឹម សុធារិទ្ធ

ប្រហែលអាចមានទាក់ទងនឹង **បុស្ករាក្ស** (Puṣkarākṣa) ដែលជាព្រះអង្គម្ចាស់នៅ **អនិន្ទិតបុរ** (Aninditapura) និងជាព្រះរាជានៅសម្ភុបុរ (çambhubura) (សម្បូណ៌ ខេត្តក្រចេះ)។

នាម "**បុស្ករាក្ស**" នេះមាននិយាយនៅក្នុងសិលាចារឹកប្រាសាទប្រែរូប (K.806) ថាជាកូនរបស់ព្រះបាទនួបតិវរ្ម័ន ដែលធ្លាប់គ្រប់គ្រងនៅអនិន្ទិតបុរ ហើយជាប់ខ្សែស្រឡាយ ឬជាជូនតារបស់ព្រះបាទរាជេន្ទ្រវរ្ម័នទី២។ ទាក់ទងនឹងព្រះនាម បុស្ករាក្ស លោកឌុយប៉ុង (Pierre Dupont) បានបកស្រាយយ៉ាងលម្អិតនៅក្នុងអត្ថបទគាត់បោះពុម្ពនៅឆ្នាំ១៩៤៣ ដោយអះអាងថាព្រះបាទបុស្ករាក្ស គឺជាស្ដេចដែលគ្រងរាជ្យនៅសម្ភុបុរ ហើយបន្តខ្សែស្រឡាយមកព្រះបាទជ័យវរ្ម័នទី២ ដែលជាព្រះរាជាគ្រងរាជ្យនៅអង្គរ។[៣]



រូបលេខ១



រូបលេខ២



រូបលេខ៣



រូបលេខ៤

[៣] Dupont 1943: 29-33



រូបលេខ២៥



រូបលេខ២៦



n. 749 / K. 121

សិលាចារឹក K.121 (CISARK http://cisark.mcfa.gov.kh)

## ឯកសារយោង


ព្រាប ចាន់ម៉ារ៉ា

២០២០. *វិមានអណ្តែត*. នៅក្នុង Grégory Mikaelian, Siyonn Sophearith, Ashley Thompson (éds.), *កម្រងអត្ថបទរំឭកគុណចំពោះលោកគ្រូ អាំង ជូលាន*, *Péninsule/Association des Amis de Yosothor*, Paris, pp. 85-103។

Finot, L.

1904. "Notes d'épigraphie (Inscription de Praḥ Thāt Kvan Pi)," *BEFEO* (4), pp. 672-679.

Dupont, P.

1943. "La dislocation du Tchen-la et la formation du Cambodge angkorien (VII$^{e}$-IX$^{e}$ siècle), *BEFEO* (43), pp. 17-55.